**ធម្មទេសនារបស់លោកអភិបាលអូលីវីយេ**
**អភិបូជាបុណ្យព្រះនាងម៉ារីនៃទន្លេមេគង្គនៅអរិយក្សត្រ**
**ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៧**
*យើងរួមគ្នាទៅជាអ្នកបម្រើរបស់ព្រះជាម្ចាស់*

អត្ថបទទី១៖ អគ ៣៤,១១-១២.១៥-១៧
អត្ថបទទី២៖ ១ករ ១៥,២០-២៦.២៨
ដំណឹងល្អ៖ មថ ២៥,៣១-៤៦

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះ យើងមានអំណរសប្បាយដោយសារ យើងគោរពព្រះយេស៊ូជាព្រះមហាក្សត្រនៃពិភពលោក។ នៅពេលព្រះសហគមន៍ឲ្យយើងមើល ព្រះយេស៊ូជាព្រះមហាក្សត្រ យើងស្តាប់អំពីព្រះគម្ពីរស្តីពី ព្រះមហាក្សត្រដែលវិនិច្ឆ័យមនុស្សលោក។ ខ្ញុំជឿថា ប្រហែលពេលបងប្អូន បានសួរខ្លួនឯងថា **តើខ្ញុំជាពពែឬជាចៀម?** ដោយសារពីដើមរៀងមក យើងថាពពែជាសត្វនៅខាងឆ្វេងដៃព្រះមហាក្សត្រ ចៀមនៅខាងស្តាំដៃមហាក្សត្រ មានន័យថាចៀមបានធ្វើតាមព្រះហឫទ័យព្រះជាម្ចាស់ ដោយបំពេញធម៌មេត្តាករុណារបស់ព្រះអង្គ និងពពែបានធ្វើខុសនឹងព្រះហឫទ័យរបស់ព្រះជាម្ចាស់ ដោយមិនចេះស្រឡាញ់តាមព្រះហឫទ័យរបស់ព្រះអង្គទេ។ អ្វីដែលជាសំខាន់សម្រាប់យើងទាំងអស់ ដែលជាគ្រីស្តបរិស័ទគឺស្តាប់សំណួររបស់ព្រះមហាក្សត្រ ដោយសារព្រះមហាក្សត្រមានសំណួរតែមួយ។ មានន័យថាព្រះយេស៊ូ មានសំណួរតែមួយសម្រាប់យើង **តើយើងយកចិត្តទុកដាក់ស្រឡាញ់បងប្អូនឯទៀតៗឬអត់?** វាមិនទាន់ហួសពេលទេ ដែលព្រះយេស៊ូរៀបចំខ្លួនរបស់យើង នៅពេលយើងទទួលមរណភាព យើងស្តាប់សំណួរហ្នឹង យើងមានពេលចាប់ពីពេលនេះតទៅដើម្បីត្រៀមខ្លួន។

ថ្ងៃនេះ យើងជួបជុំគ្នានៅអរិយក្សត្រដែលយើងគោរពព្រះនាងម៉ារីនៃទន្លេមេគង្គ ជាឱកាសមួយដែលយើងមើលរបៀបព្រះនាងម៉ារី។ ព្រះនាងម៉ារី ដែលបានធ្វើដំណើរជាមួយព្រះយេស៊ូ តាំងពីថ្ងៃកំណើតរហូតដល់ព្រះនាងម៉ារីនៅក្បែរឈើឆ្កាង កំពុងសម្លឹងមើលកូនផ្ទាល់ដែលកំពុងសោយទិវង្គត។ កន្លែងនេះជាកន្លែងអស្ចារ្យមួយ ព្រះនាងម៉ារីទី១ដែលយើងបានរកឃើញ គឺអ្នកនេសាទអ៊ីស្លាមដែលបានជាប់នៅក្នុងសំណាញ់របស់គាត់ ក្នុងទន្លេមេគ

ង្គ និងរកឃើញព្រះនាងម៉ារីនៅថ្ងៃចូលឆ្នាំខ្មែរ នៅថ្ងៃទី១៦ ខែមេសា ឆ្នាំ២០០៨ ជាថ្ងៃខួបកំណើតរបស់សម្តេចប៉ាបបេណេឌីកតូទី១៦។ ព្រះនាងម៉ារីទី២ ដែលយើងគោរពថ្ងៃនេះ គឺជាប្តីប្រពន្ធជាពុទ្ធបរិស័ទ នៅក្នុងយល់សុបិនបីយប់ជាប់គ្នា ប្តីបានឃើញព្រះយេស៊ូបីដងដែលបង្ហាញកន្លែងមួយឲ្យទៅ ហើយប្រពន្ធរបស់គាត់ថា ឲ្យទៅមើលទៅ ហើយគាត់បានរកឃើញរូបព្រះនាងម៉ារីធំដែលយើងគោរពថ្ងៃនេះ គឺនៅថ្ងៃដែលព្រះនាងម៉ារីថ្វាយខ្លួននៅព្រះវិហារយេរូសាឡឹម។

ការអស្ចារ្យមានច្រើន ដែលបងប្អូនជាសាក្សីផ្ទាល់ នៅក្នុងភូមិភាគភ្នំពេញយើងបានទទួលការអស្ចារ្យមួយ នៅក្នុងខែកក្កដា ឆ្នាំ២០១៧នេះ នៅក្នុងភូមិខ្មែរខាងកំពត ឆ្ងាយពីនេះ១៥០គីឡូម៉ែត្រ មានយាយម្នាក់ដែលជាគ្រីស្តបរិស័ទ គាត់មានបញ្ហាភ្នែកពីយូរហើយ ប៉ុន្តែនៅដើមខែកក្កដា គាត់ដួលគាត់ធ្លាក់ឈាមលែងដើរបាន ជាប់សរសៃនៅខាងស្តាំ។ គាត់ចូលមន្ទីរពេទ្យ៥ថ្ងៃ ប៉ុន្តែអត់បានព្យាបាលអ្វីសោះ និងគាត់អស់លុយ គាត់ទៅផ្ទះវិញដោយយំ ឲ្យគាត់ទូលអង្វរព្រះនាងម៉ារីថា "**ថាភ្នែកខ្ញុំមើលអត់សូវឃើញ ឥឡូវនេះខ្ញុំដើរមិនរួច បពិត្រព្រះនាងម៉ារីអើយសូមជួយខ្ញុំផង ឱព្រះយេស៊ូអើយសូមអាណិតខ្ញុំផង**" នៅថ្ងៃព្រហស្បត៏ ទី២០ ខែកក្កដា ឆ្នាំ២០១៧នេះ នៅក្នុងយល់សុបិន ម៉ោង៤ជិតភ្លឺ គាត់ឃើញព្រះនាងម៉ារីទាំងពីរនៅទីនេះកំពុងឈរមើលគាត់។ គាត់ថា ព្រះនាងម៉ារីពាក់អាវសយ៉ាងស្អាត និងមានបងស្រីមារីនៅក្រុមបងស្រីឧបការគុណ ដែលកំពុងអង្គុយនៅក្នុងយល់សុបិននេះ ជាមួយព្រះនាងម៉ារីនិងយាយនេះ។ បងស្រីម៉ារី ប្រាប់ដល់យាយថា ព្រះនាងម៉ារីថាកុំអធិដ្ឋានផ្តាំតែ៥០ សូមអធិដ្ឋានច្រើនទៅគឺ១០០។ ក្រោយមកបងស្រីម៉ារី យកប្រេងក្រឡាលាបជើងយាយ ហើយប្រាប់យាយថា សូមយាយឈរឡើងទៅ ពេលយាយភ្ញាក់ពីដេក ហើយដើរបានពិតមែន។

ការអស្ចារ្យរបស់ព្រះនាងម៉ារីនៅអរិយក្សត្រមានច្រើនដែរ និងការអស្ចារ្យមួយដ៏ពិសេសសម្រាប់យើងទាំងអស់ គឺថ្ងៃនេះយើងជួបជុំគ្នាយ៉ាងច្រើន ដើម្បីគិតពិចារណា **តើយើងធ្វើយ៉ាងម៉េច ដើម្បីទៅជាសញ្ញាសម្គាល់នៃព្រះរាជ្យរបស់ព្រះជាម្ចាស់ ដែលកំពុងយាងមកតាមរយៈព្រះយេស៊ូគ្រីស្ត ដើម្បីឲ្យបងប្អូនយើងទាំងនៅប្រទេសកម្ពុជា ទាំងនៅប្រទេសវៀតណាម មើលឃើញព្រះរាជ្យរបស់ព្រះជាម្ចាស់យ៉ាងជាក់ស្តែង?** សម្រាប់យើងទាំងអស់ជាពេលវេលាមួយ ដើម្បីនិយាយ សច្ចារម្តងទៀតតាមរបៀបព្រះនាងម៉ារី «**ខ្ញុំយកព្រះជា**

**ម្ចាស់ជាទីពឹងសម្រាប់ជីវិតរបស់ខ្ញុំ**»។ ព្រះនាងម៉ារី នៅពេលឪពុកម្តាយរបស់គាត់ បានថ្វាយគាត់នៅព្រះវិហារយេរូសាឡឹម នៅពេលនោះព្រះនាងម៉ារីមានអាយុ៣ឆ្នាំ។ ពីអាយុ៣ឆ្នាំរហូតអាយុ១២ឆ្នាំ ព្រះនាងម៉ារីបាននៅព្រះវិហារយេរូសាឡឹម ដើម្បីកោតសរសើរព្រះជាម្ចាស់ ដើម្បីទទួលសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ដ៏ពេញលក្ខណៈ។ ហេតុនេះហើយព្រះជាម្ចាស់បានជ្រើសរើសព្រះនាងម៉ារីជាមាតារបស់ព្រះយេស៊ូ ហេតុនេះហើយ ព្រះនាងម៉ារីបានឆ្លើយតប «**ខ្ញុំសុខចិត្តធ្វើជាអ្នកបម្រើរបស់ព្រះអង្គ**» ហេតុនេះហើយព្រះនាងម៉ារីមានអំណរសប្បាយពេញខ្លួន ដើម្បីចែករំលែកដំណឹងល្អនេះទៅយាយអេលីសាបែត។ ព្រះនាងម៉ារីបានជ្រើសរើសព្រះជាម្ចាស់ ដើម្បីទីពឹងលើព្រះអង្គអស់មួយជីវិតរបស់គាត់ និងព្រះនាងម៉ារីនៅជាមួយព្រះយេស៊ូតែប៉ុណ្ណឹង។ នៅពេលព្រះយេស៊ូមានព្រះបន្ទូលថា «**អ្នកណាជាម្តាយខ្ញុំ**» ព្រះនាងម៉ារីមិនខឹងទេ មិនអន់ចិត្តទេ ដោយសារព្រះនាងម៉ារីដឹងហើយថា ម្តាយនិងបងប្អូនរបស់ព្រះយេស៊ូ គឺ**អ្នកដែលធ្វើតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់ជានិច្ច**។ នេះជាអ្វី ដែលព្រះនាងម៉ារីខិតខំធ្វើអស់មួយជីវិតរបស់គាត់ ជ្រើសរើសព្រះជាម្ចាស់មុនគេបង្អស់ជាអាទិភាពនៅក្នុងជីវិត។

ព្រះនាងម៉ារី មានចរិតមួយពិសេសគឺ**ដាក់ខ្លួន** ព្រះនាងម៉ារីមានអំណរសប្បាយផងដាក់ខ្លួនផង ចិត្តបម្រើជានិច្ច និងទទួលទុក្ខលំបាក ដោយសារថ្ងៃចុងក្រោយ ព្រះនាងម៉ារីនៅក្បែរឈើឆ្កាងកំពុងមើលកូនផ្ទាល់ដែលកំពុងសោយទិវង្គត។ ហេតុនេះហើយ ដាក់ខ្លួនអំណរសប្បាយដោយសារជាមួយព្រះជាម្ចាស់ បម្រើជានិច្ច ទុក្ខលំបាកដែលមាន អាចជោគជ័យបាន ដោយសារព្រះនាងម៉ារីបានជ្រើសរើសព្រះជាម្ចាស់ជាអាទិភាពបំផុត នៅក្នុងជីវិតរបស់ព្រះនាង។ យើងទាំងអស់គ្នាត្រូវនិយាយម្តងទៀត ជាមួយព្រះនាងម៉ារី «**ខ្ញុំជាអ្នកបម្រើរបស់ព្រះជាម្ចាស់**»។ ខ្ញុំជាអ្នកបម្រើរបស់ព្រះជាម្ចាស់ ដូចព្រះនាងម៉ារី យើងទាំងអស់គ្នាយើងអាចឆ្លើយទៅព្រះយេស៊ូ ដើម្បីបង្ហាញអំពីសេចក្តីស្រឡាញ់ដែលយើងមានដល់អ្នកតូចតាច អស់មួយជីវិតរបស់យើង នៅពេលព្រះយេស៊ូសួរយើងថា **តើយើងបានបងប្អូនឯទៀតៗឬទេ?**

នៅថ្ងៃនេះ ខ្ញុំអធិដ្ឋានទូលអង្វរព្រះជាម្ចាស់ សម្រាប់ព្រះសហគមន៍របស់យើង ឲ្យរួមគ្នាទៅជាអ្នកបម្រើរបស់ព្រះជាម្ចាស់ ដើម្បីទៅជាសញ្ញាសម្គាល់ អំពីព្រះរាជ្យរបស់ព្រះជាម្ចាស់ដែលកំពុងយាងមក។ ព្រះរាជ្យរបស់ព្រះជាម្ចាស់នៅទីនេះ នៅក្នុងដួងចិត្តរបស់យើង

ជាវត្តមានរបស់ព្រះយេស៊ូ នេះជាព្រះរាជ្យរបស់ព្រះជាម្ចាស់។ ដូច្នេះកុំឲ្យយើងទៅមើលគេទៅមើលកន្លែងមួយយ៉ាងពិសេស ឲ្យយើងមើលនៅក្នុងដួងចិត្តរបស់យើង។ ព្រះយេស៊ូបានជ្រើសរើសយើង ធ្វើជាព្រះដំណាក់ដើម្បីស្ថិតនៅក្នុងដួងចិត្តរបស់យើង ហេតុនេះហើយព្រះរាជ្យរបស់ព្រះជាម្ចាស់នៅទីនេះ។ ឲ្យយើងបើកដួងចិត្តឲ្យទូលំទូលាយ ដើម្បីឲ្យបងប្អូនទាំងអស់បានឃើញ សេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់ ដែលចេញពីដួងចិត្តរបស់យើងជាប្រចាំថ្ងៃ។ ខ្ញុំអធិដ្ឋានទូលអង្វរព្រះជាម្ចាស់ ដើម្បីឲ្យយើងទទួលព្រះពរ សម្រាប់ព្រះសហាគមន៍យើងទាំងអស់ឲ្យយើងមានសេចក្ដីសុខ និងជាពិសេសឲ្យយើងទៅជាសាក្សីនៃសេចក្ដីសង្ឃឹម។ ព្រះជាម្ចាស់ស្រឡាញ់យើងយ៉ាងខ្លាំងណាស់ ឲ្យយើងចេះស្រឡាញ់ ព្រះនាងម៉ារីជាមាតារបស់យើង ឲ្យយើងចេះធ្វើតាមព្រះមាតារបស់យើងជានិច្ច។ អាម៉ែន៕